ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៨០៥៧ សហវ.អលស

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ស្តីពីការងារស្ថាបនាផ្លូវក្រាលខ្សាច់ក្រួសក្រហមកាច់ចំនួន ០១ ខ្សែ ប្រវែង ៨ ០០០ម ទទឹងខ្នងលើ ៦ម សាងសង់លូប្រអប់ចំនួន ០១កន្លែង លូមូលចំនួន ១៤កន្លែង និងសាងសង់ស្លាកឈ្មោះផ្លូវចំនួន ០២កន្លែង ស្ថិតនៅខេត្តព្រៃវែង។

**យោង:**
- លិខិតលេខ ៤៥០០ សហវ.អថ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ០៩២១/១៧ ក.អ.ជ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារស្ថាបនាផ្លូវក្រាលខ្សាច់ក្រួសក្រហមកាច់ចំនួន ០១ខ្សែ ប្រវែង ៨ ០០០ម ទទឹងខ្នងលើ ៦ម សាងសង់លូប្រអប់ចំនួន ០១កន្លែង សាងសង់លូមូលចំនួន ១៤កន្លែង និងសាងសង់ផ្លាកឈ្មោះផ្លូវចំនួន ០២កន្លែង ស្ថិតនៅឃុំអង្គររាជ ស្រុកព្រះស្តេច ខេត្តព្រៃវែង ក្នុងតម្លៃសរុបចំនួន ២ ៩៨៤ ០០០ ០០០រៀល (ពីរប៊ីលានប្រាំបួនរយប៉ែតសិបបួនលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន:**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
- នាយកដ្ឋានផ្លូវលំជនបទ
- សាលាខេត្តព្រៃវែង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រៃវែង
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798